01429650

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Preliminaire

ឯកសារលេខD277/1/1/4

*តាមនាមប្រជារាស្ត្រខ្មែរ និងតាមនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ*

សំណុំរឿងព្រហ្មទណ្ឌលេខ: ០០៤/២/០៧-០៩-២០០៩-អវតក/កសចស (អបជ ៣៤)

ចំពោះមុខ: ចៅក្រម ប្រាក់ គឹមសាន ជាប្រធាន
ចៅក្រម Olivier BEAUVALLET
ចៅក្រម នីយ ថុល
ចៅក្រម Kang Jin BAIK
ចៅក្រម ហួត វុទ្ធី

កាលបរិច្ឆេទ: ថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៧

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 03/04/2017
ម៉ោង (Time/Heure): 14:05
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

សាធារណៈ:កោសលុប

# សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរលើកទី ៧ របស់ [redacted]

**សហព្រះរាជអាជ្ញា**

ជា លាង
Nicholas KOUMJIAN

**សហមេធាវីការពារក្តីម្ចាស់បណ្តឹងឧទ្ធរណ៍**

មុំ លុច
Richard ROGERS
Göran SLUITER

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

ជេត វណ្ណលី
ហុង គីមសួន
គីម ម៉េងឃី
ឡោ ជុនធី
សំ សុគង់
ស៊ិន សុវ៉ន
ទី ស្រីនណា
វេន ពៅ
Laure DESFORGES
Isabelle DURAND
Emmanuel JACOMY
Martine JACQUIN
Lyma NGUYEN
Nushin SARKARATI

អង្គបុរេជំនុំជម្រះ PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

**អង្គបុរេជំនុំជម្រះ**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានទទួល"បណ្តឹងឧទ្ធរណ៍លើសេចក្តីសម្រេចលើសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរលើកទី៧ របស់ [redacted]" ដែលបានដាក់ដោយសហមេធាវី [redacted] ("ម្ចាស់បណ្តឹងឧទ្ធរណ៍" និង "សហមេធាវី" ឬ "មេធាវីការពារក្តី") កាលពីថ្ងៃទី៦ ខែមករា ឆ្នាំ២០១៧ ("បណ្តឹងឧទ្ធរណ៍")[1]។

## I. **សេចក្តីផ្តើម**

1. បណ្តឹងឧទ្ធរណ៍នេះទាក់ទងនឹងសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិដែលបានចេញកាលពីថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០១៦ ដោយបដិសេធត្រង់ផ្នែកខ្លះលើសំណើលើកទីប្រាំពីររបស់ម្ចាស់បណ្តឹងឧទ្ធរណ៍សុំបំពេញកិច្ចស៊ើបសួរ ("ដីកាសម្រេចដែលត្រូវបានជំទាស់")[2]។

## II. **ប្រវត្តិនីតិវិធី**

2. កាលពីថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០០៩ សហព្រះរាជអាជ្ញាអន្តរជាតិស្តីទីបានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបីជូនការិយាល័យសហចៅក្រមស៊ើបអង្កេតដោយបានចោទប្រកាន់អំពីការចូលរួមពាក់ព័ន្ធរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍នៅក្នុងអំពើល្មើស និងការស្នើសុំឱ្យដាក់បទចោទប្រឆាំង [redacted][3]។

3. កាលពីថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ ២០១៥ សហមេធាវីបានដាក់សំណើសុំបំពេញកិច្ចស៊ើបសួរដោយបានស្នើសុំការសាកសួរទាំងមូលលើ៖ (ក) សមាសភាព រចនាសម្ព័ន្ធ និងថ្នាក់ដឹកនាំរបស់មជ្ឈិមភូមិភាគឧត្តរចាស់ និងកងសន្តិសុខ និងយោធាតំបន់ ១០៦ ដែលបើកប្រតិបត្តិការណ៍នៅភូមិភាគ

---

[1] បណ្តឹងឧទ្ធរណ៍លើសេចក្តីសម្រេចលើសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរលើកទី៧ របស់ [redacted] ចុះថ្ងៃទី៦ ខែមករា ឆ្នាំ២០១៧ ឯកសារ D277/1/1/2 ("បណ្តឹងឧទ្ធរណ៍")។

[2] ដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរលើកទីប្រាំពីររបស់ [redacted] ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០១៦ D277/1 ("ដីកាសម្រេចដែលត្រូវបានជំទាស់")។

[3] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបី របស់សហព្រះរាជអាជ្ញា ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ ឯកសារ D1។ សូមមើលផងដែរ សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី អំពីការដាក់ឯកសារស្តីពីដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទី៣ ថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០០៩ ឯកសារ D1/1។

កណ្តាលនៅក្នុងពេលដែលមានការចោទប្រកាន់អំពីការបោសសម្អាត (ខ) ការជាប់ពាក់ព័ន្ធនឹងកងទ័ពទាំងនេះនៅក្នុងការចោទប្រកាន់អំពីការបោសសំអាត និង (គ) ការគ្រប់គ្រងរបស់ [redacted] និងការទទួលខុសត្រូវលើអំពើរបស់កងទ័ពទាំងនេះ ("សំណើសុំលើកទី ៧")[4]។

4. នៅថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០១៦ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចេញដីកាសម្រេចដែលត្រូវបានជំទាស់ដោយបានជូនដំណឹងដល់សហមេធាវីថា កិច្ចស៊ើបសួរដែលបានស្នើសុំត្រូវបានបំពេញគ្រប់ផ្នែកខ្លះរួចហើយ ហើយបានច្រានចោលផ្នែកដែលនៅសេសសល់នៅក្នុងសំណើសុំលើកទីប្រាំពីរ[5]។

5. នៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៦ សហមេធាវីបានដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចដែលត្រូវបានជំទាស់[6]។

6. នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានដាក់សេចក្តីជូនដំណឹងអំពីការបញ្ចប់កិច្ចស៊ើបសួរ[7]។

7. នៅថ្ងៃទី៤ ខែមករា ឆ្នាំ២០១៧ សហមេធាវីបានដាក់សំណើសុំដាក់បណ្តឹងឧទ្ធរណ៍ជាភាសាអង់គ្លេសជាមុនសិនដោយសំណៅបកប្រែជាភាសាខ្មែរនឹងដាក់ជូនតាមក្រោយ[8]។ នៅថ្ងៃទី៦ ខែមករា ឆ្នាំ២០១៧ សហមេធាវីបានដាក់បណ្តឹងឧទ្ធរណ៍ជាភាសាអង់គ្លេសតែប៉ុណ្ណោះ ហើយសំណៅបកប្រែជាភាសាខ្មែរត្រូវបានដាក់នៅថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១៧។ នៅថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០១៧ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់ចម្លើយតបរបស់គាត់ទៅនឹងបណ្តឹងឧទ្ធរណ៍("ចម្លើយតប")[9]។ ការឆ្លើយតបពុំត្រូវបានដាក់នៅក្នុងកាលបរិច្ឆេទកំណត់តាមផ្លូវច្បាប់នោះឡើយ។

---

4 សំណើសុំបំពេញកិច្ចស៊ើបសួរលើកទីប្រាំពីរ កថាខណ្ឌ ៥២ កថាខណ្ឌ ៥៣។

5 ដីកាសម្រេចដែលត្រូវបានជំទាស់ កថាខណ្ឌ ៥២ កថាខណ្ឌ ៥៣។

6 សៀវភៅចុះបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរលើកទីប្រាំពីររបស់ [redacted] ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៦ D277/1/1។

7 សេចក្តីជូនដំណឹងអំពីការបិទកិច្ចស៊ើបសួរប្រឆាំង [redacted] ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ឯកសារ D334។

8 សំណើសុំអនុញ្ញាត ដើម្បីដាក់ជាភាសាអង់គ្លេសជាមុននូវបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងសេចក្តីសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរលើកទីប្រាំពីររបស់ [redacted] ចុះថ្ងៃទី៤ ខែមករា ឆ្នាំ២០១៧ D277/1/1/1។

9 ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរលើកទីប្រាំពីររបស់ គាត់ ចុះថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០១៧ D277/1/1/3 ("ចម្លើយតប")។

## III. ភាពអាចទទួលយកបាន

8. សហមេធាវីបានដាក់សេចក្ដីជូនដំណឹងអំពីបណ្ដឹងឧទ្ធរណ៍ស្របតាមរយៈពេលកំណត់ដូចមានចែងនៅក្នុងវិធាន ៧៥(១) នៃវិធានផ្ទៃក្នុង។ នៅថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៧ អង្គបុរេជំនុំជម្រះក្រោយពីបានពិចារណាលើហេតុផល ហើយដោយគ្មានការជំទាស់ត្រូវបានលើកឡើងនោះ សំណើសុំដាក់តែមួយភាសា និងអនុលោមតាមវិធាន ៣៩(៤) នៃវិធានផ្ទៃក្នុង និងមាត្រា ៧.២ នៃសេចក្ដីណែនាំអនុវត្តស្ដីពីការដាក់ឯកសារអនុញ្ញាតឲ្យដាក់បណ្ដឹងឧទ្ធរណ៍ជាភាសាអង់គ្លេសតែមួយភាសាបាន។ អង្គបុរេជំនុំជម្រះយល់ស្របផងដែរជាមួយនឹងសហមេធាវី[10]ថា បណ្ដឹងឧទ្ធរណ៍នេះអាចទទួលយកបានអនុលោមតាមវិធាន ៧៤(៣)(ខ) នៃវិធានផ្ទៃក្នុងដោយសារសំណើសុំលើកទីប្រាំពីរត្រូវបានដាក់អនុលោមតាមវិធាន ២១ វិធាន ៥៥(១០) និងវិធាន ៥៨(៦) នៃវិធានផ្ទៃក្នុង ហើយបានស្នើសុំឲ្យសហចៅក្រមស៊ើបអង្កេតបំពេញកិច្ចក្នុងគោលបំណងប្រមូលព័ត៌មាន[11]។

## IV. បទដ្ឋាននៃការពិនិត្យមើលឡើងវិញ

9. អនុលោមតាមយុត្តិសាស្ត្ររបស់អង្គបុរេជំនុំជម្រះ ដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអាចច្រានចោលវិញបានប្រសិនបើដីកាសម្រេចនោះ៖ ក) បានផ្អែកលើកំហុសអង្គច្បាប់ដែលនាំឲ្យមោឃៈដីកាសម្រេច ខ) បានផ្អែកលើកំហុសអង្គហេតុដែលនាំឲ្យមានកំហុសនៅក្នុងស្វែងរកយុត្តិធម៌ ឬ គ) មានភាពអយុត្តិធម៌ ឬ ពុំសមហេតុផលដែលនាំឲ្យមានការបំពានឆន្ទានុសិទ្ធិរបស់ចៅក្រម[12]។

---

[10] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ១៧។

[11] *សូមមើល ឧ.* សំណុំរឿង ០០២/១៩-០៩-២០០៧-ក.ស.ច.ស ("សំណុំរឿង ០០២") (អ.ប.ជ ១១) សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់លោក ខៀវ សំផន ប្រឆាំងនឹងដីកាសម្រេចស្ដីពីសិទ្ធិ និងកាតព្វកិច្ចរបស់ភាគីទាក់ទងនឹងការបកប្រែ ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០៩ ឯកសារ A190/I/20 កថាខណ្ឌ ២៨។

[12] *សូមមើល ឧ.* សំណុំរឿង ០០៤/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ("សំណុំរឿង ០០៤") (អ.ប.ជ ២៤) សេចក្ដីពិចារណាលើដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្ដីសម្រេចលើសំណើសុំលើកទីប្រាំពីររបស់ [redacted] សុំបំពេញកិច្ចស៊ើបសួរ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៦ ឯកសារ A260/1/1/3 ("សេចក្ដីពិចារណាលើសំណើសុំបំពេញកិច្ចស៊ើបសួរលើកទីប្រាំ") កថាខណ្ឌ ១៥។

10. អង្គបុរេជំនុំជម្រះសូមរំលឹកផងដែរថា ដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតលើសំណើសុំបំពេញកិច្ចស៊ើបសួរគឺជាដីកាសម្រេចធ្វើឡើងតាមឆន្ទានុសិទ្ធិ។ ដើម្បីអាចឱ្យអង្គបុរេជំនុំជម្រះច្រានចោលការអនុវត្តឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេតបាននោះម្ចាស់បណ្តឹងឧទ្ធរណ៍ត្រូវបង្ហាញថាដីកាសម្រេចដែលត្រូវបានជំទាស់នោះបាន៖ (១) បានផ្អែកលើការបកស្រាយមិនត្រឹមត្រូវលើច្បាប់ជាធរមាន (២) បានផ្អែកលើការសន្និដ្ឋានលើអង្គហេតុមិនត្រឹមត្រូវយ៉ាងជាក់ស្តែង និង/ឬ ពុំមានភាពយុត្តិធម៌ឬពុំសមហេតុផលដែលនាំឱ្យមានការបំពានឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេត។ គ្មានកំហុសទាំងអស់នឹងនាំឱ្យអង្គបុរេជំនុំជម្រះច្រានចោលដីកាសម្រេចរបស់សហចៅក្រម ស៊ើបអង្កេតបាននោះទេ។ កំហុសនោះត្រូវជាកត្តាកំណត់ជាសារវន្តលើការអនុវត្តឆន្ទានុសិទ្ធិដែលនាំឱ្យចេញដីកាសម្រេចដែលត្រូវបានប្តឹងឧទ្ធរណ៍[13]។

## V. ច្បាប់ជាធរមាន

11. វិធាន ៥៥(១០) នៃវិធានផ្ទៃក្នុងចែងអំពីសិទ្ធិរបស់ភាគីក្នុងការស្នើសុំបំពេញកិច្ចស៊ើបសួរ៖

> នៅគ្រប់ពេលវេលានៃការស៊ើបសួរ សហព្រះរាជអាជ្ញា ជនត្រូវចោទ ឬ ដើមបណ្តឹងរដ្ឋប្បវេណីអាចស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេតចេញដីកា ឬ បំពេញកិច្ចស៊ើបសួរណាមួយដែលខ្លួនយល់ឃើញថាមានប្រយោជន៍ដល់ការស៊ើបសួរ។ ប្រសិនបើសហចៅក្រមស៊ើបអង្កេតមិនយល់ព្រម សហចៅក្រមស៊ើបអង្កេតត្រូវចេញដីកាបដិសេធឱ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន ហើយ នៅគ្រប់ករណីទាំងអស់ត្រូវចេញដីកានេះឱ្យបានមុនពេលបញ្ចប់កិច្ចស៊ើបសួរ។ ដីកាបដិសេធនេះ ត្រូវមានសំអាងហេតុ ហើយត្រូវជូនដំណឹងដល់ភាគី។ ដីកាបដិសេធនេះបើកផ្លូវឱ្យប្តឹងឧទ្ធរណ៍។

---

[13] សេចក្តីពិចារណាលើសំណើសុំបំពេញកិច្ចស៊ើបសួរលើកទីប្រាំ កថាខណ្ឌ ១៦ *ដែលយោងលើ*សំណុំរឿង ០០២ (អ.ប.ជ ២៤) សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុកឯកសាររួម ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៩ ឯកសារ D164/4/13 ("សាលដីកាលើឃ្លាំងផ្ទុកឯកសាររួម") កថាខណ្ឌ ២៥ ដល់ កថាខណ្ឌ ២៧។ សំណុំរឿង ០០២ (អ.ប.ជ ៦២) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់សហមេធាវីការពារក្តី អៀង ធីរិទ្ធ ប្រឆាំងនឹង "ដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួររបស់សហមេធាវីការពារក្តី អៀង ធីរិទ្ធ" ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១០ ឯកសារ D353/2/3 ("សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ") កថាខណ្ឌ ៨។ សំណុំរឿង ០០២ (អ.ប.ជ ៦៧) សាលដីកាលើស្តីពីការពិចារណាឡើងវិញទៅលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតទៅលើសំណើសុំដាក់បញ្ចូលឯកសារភស្តុតាងបន្ថែមទៅក្នុងសំណុំរឿងដែលនឹងជួយដល់ការបញ្ជាក់ពីការដឹងឮរបស់ជនត្រូវចោទចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១០ ឯកសារ D365/2/17 ("សាលដីកាស្តីពីការពិចារណាឡើងវិញលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា") កថាខណ្ឌ ២៦ កថាខណ្ឌ ៥៥ ដល់ កថាខណ្ឌ ៥៨។

12. វិធាន ៥៨(៦) នៃវិធានផ្ទៃក្នុងចែងថា៖

> ក្នុងអំឡុងពេលស៊ើបសួរ ជនត្រូវចោទអាចស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេតសួរចម្លើយខ្លួន ស្តាប់ចម្លើយសាក្សី ចុះទៅដល់កន្លែងកើតហេតុ បង្គាប់ឱ្យធ្វើកោសល្យវិច័យ ឬ ប្រមូលយកភស្តុតាងផ្សេងទៀត។ សំណើនេះត្រូវធ្វើជាលាយលក្ខណ៍អក្សរដោយមានបញ្ជាក់មូលហេតុពិតប្រាកដ។ ប្រសិនបើសហចៅក្រមស៊ើបអង្កេតមិនយល់ព្រមតាមសំណើសុំនេះទេ សហចៅក្រមស៊ើបអង្កេតត្រូវចេញដីកាបដិសេធឱ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន និងនៅគ្រប់ករណីទាំងអស់ ត្រូវចេញដីកាបដិសេធនេះនៅមុនពេលបញ្ចប់កិច្ចស៊ើបសួរ។ ដីកាបដិសេធត្រូវមានសំអាងហេតុ។ ជនត្រូវចោទត្រូវបានជូនដំណឹងជាបន្ទាន់អំពីដីកាបដិសេធនេះ ជនត្រូវចោទអាចធ្វើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកានេះទៅអង្គបុរេជំនុំជម្រះ។

13. អង្គបុរេជំនុំជម្រះបានសម្រេចថា លក្ខខណ្ឌត្រូវ[14]ចំនួនពីរត្រូវបំពេញដើម្បីអាចឱ្យសហចៅក្រមស៊ើបអង្កេតអាចយល់ស្របតាមសំណើសុំ៖ (i) លក្ខខណ្ឌស្តីពីភាពជាក់លាក់ និងលក្ខខណ្ឌស្តីពីភាពពាក់ព័ន្ធ*បឋម*។ អង្គបុរេជំនុំជម្រះរកឃើញថា "បទប្បញ្ញត្តិវិធាន ៥៥(១០) នៃវិធានផ្ទៃក្នុងចែងមិនច្បាស់ថាតើវិធាននេះត្រូវយកមកអនុវត្តស្របគ្នានឹងវិធាន ៥៨(៦) នៃវិធានផ្ទៃក្នុង។ បើតាមវិធាន ៥៥(១០) នេះ ភាគីដែលដាក់សំណើសុំត្រូវកំណត់ឱ្យច្បាស់នូវការស្នើសុំបំពេញកិច្ចស៊ើបសួរ និងរៀបរាប់មូលហេតុដែលភាគីស្នើសុំយល់ឃើញថា មានភាពចាំបាច់សម្រាប់ដឹកនាំការស៊ើបអង្កេត"[15]។ អង្គបុរេជំនុំជម្រះសូមរំលឹកថា ដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតលើសំណើសុំបំពេញកិច្ចស៊ើបសួរគឺជាដីកាសម្រេចធ្វើឡើងតាមឆន្ទានុសិទ្ធិដោយហេតុថា យោងតាមភារកិច្ចរួមរបស់សហចៅក្រមស៊ើបអង្កេត និងការយល់ដឹងអំពីសំណុំរឿង មានតែសហចៅក្រមស៊ើបអង្កេតតែប៉ុណ្ណោះដែលអាចមានលទ្ធភាពប្រសើរបំផុតក្នុងការវាយតម្លៃថាតើសំណើសុំនេះពិតជាជួយដល់ការបញ្ជាក់ការពិតដែរឬយ៉ាងណា[16]។

---

[14] សំណុំរឿង ០០២ (អ.ប.ជ ៦៣) សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹង "ដីកាសម្រេចលើសំណើសុំដាក់បញ្ចូលឯកសារទាំងឡាយពាក់ព័ន្ធនឹងសកម្មភាពជាក់ស្តែងរបស់លោក ខៀវ សំផន" ចុះថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០១០ ឯកសារ D370/2/11 កថាខណ្ឌ ២២។

[15] សាលដីកាលើឃ្លាំងផ្ទុកឯកសាររួម កថាខណ្ឌ ៤៤ និងលេខយោងជើងទំព័រ ៥៦។

[16] សាលដីកាស្តីពីការពិចារណាឡើងវិញលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣៦ កថាខណ្ឌ ៥៥ ដល់កថាខណ្ឌ ៥៨។ សេចក្តីពិចារណាលើសំណើសុំបំពេញកិច្ចស៊ើបសួរលើកទីប្រាំ") កថាខណ្ឌ ១៦។

## VI. អង្គសេចក្តី

14. ក្រោយពីពិនិត្យមើលឡើងវិញលើបណ្តឹងឧទ្ធរណ៍ អង្គបុរេជំនុំជម្រះពិចារណាឃើញថា កិច្ចស៊ើបសួរដែលត្រូវបានស្នើសុំឱ្យបំពេញពុំចាំបាច់ធ្វើឡើងនោះទេ។ ចៅក្រមនៃអង្គបុរេជំនុំជម្រះសូមដាក់ភ្ជាប់មតិយោបល់។

**យោងតាមសំអាងហេតុខាងលើនេះ អង្គបុរេជំនុំជម្រះសម្រេចជាឯកច្ឆន្ទ៖**

- **ទទួលយក**បណ្តឹងឧទ្ធរណ៍តាមទម្រង់ច្បាប់។
- **ច្រានចោល**បណ្តឹងឧទ្ធរណ៍លើអង្គសេចក្តី។

អនុលោមតាមវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង សាលដីកានេះពុំបើកផ្លូវឱ្យប្តឹងតវ៉ានោះទេ។

**ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៧**

**ប្រធាន** **អង្គបុរេជំនុំជម្រះ**

**ប្រាក់ គីមសាន** **Olivier BEAUVALLET** **ន័យ ថុល** **Kang Jin BAIK** **ហួត វុទ្ធី**

ចៅក្រម ប្រាក់ គីមសាន ចៅក្រម ន័យ ថុល និងចៅក្រម ហួត វុទ្ធី បានដាក់ភ្ជាប់មតិយោបល់។

ចៅក្រម Olivier BEAUVALLET និងចៅក្រម Kang Jin BAIK បានដាក់ភ្ជាប់មតិយោបល់។

01429657



## មតិយោបល់ចៅក្រម ប្រាក់ គឹម សាន ចៅក្រម និយ ថុល និងចៅក្រម ហួត វុទ្ធី

15. ចៅក្រមជាតិនៃអង្គបុរេជំនុំជម្រះ ("អ.វ.ត.ក") នឹងបង្ហាញអំពីមតិយោបល់របស់ខ្លួនទាក់ទងនឹងបណ្តឹងឧទ្ធរណ៍របស់លោក [redacted] ស្នើសុំឱ្យបំពេញកិច្ចស៊ើបសួរលើកទីប្រាំពីររបស់ [redacted]។

16. ចៅក្រមជាតិនៃអង្គបុរេជំនុំជម្រះ យល់ឃើញថា អ.វ.ត.ក ត្រូវបានបង្កើតឡើងតាម កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ (កិច្ចព្រមព្រៀង), ច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ (ច្បាប់ អ.វ.ត.ក) និងអនុវត្តវិធានផ្ទៃក្នុង។

17. អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ជាតុលាការពិសេសមួយដែលអនុវត្តនីតិវិធីនៃការចោទប្រកាន់ និងការស៊ើបសួរ ខុសពីតុលាការថ្នាក់ជាតិនៃប្រទេសកម្ពុជា។ ការចោទប្រកាន់ និងការស៊ើបសួររបស់តុលាការថ្នាក់ជាតិនៃប្រទេសកម្ពុជា គឺធ្វើឡើងតែលើអង្គហេតុទេ មានន័យថាមិនមែនជាការចោទប្រកាន់ និងការស៊ើបសួរលើបុគ្គលឡើយ[17]។ ផ្ទុយមកវិញនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ការចោទប្រកាន់ និងការស៊ើបសួរ អាចធ្វើទៅបាន លុះត្រាបំពេញលក្ខខណ្ឌពីរ គឺ ទី១.*អង្គហេតុ* "ឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ការរំលោភទៅលើច្បាប់មនុស្សធម៌អន្តរជាតិនិងទម្លាប់អន្តរជាតិ ព្រមទាំងការរំលោភលើអនុសញ្ញាអន្តរជាតិ ដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃ ១៧ មេសា ១៩៧៥ ដល់ថ្ងៃ ៦ មករា ១៩៧៩" និង ទី២.*បុគ្គល* "មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម"[18]។

---

[17] មាត្រា ៤៤ និង ១២៥ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា។

[18] មាត្រា ១ នៃច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ, មាត្រា ១ នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ និងវិធាន ៥៣ នៃវិធានផ្ទៃក្នុង។

18. សហព្រះរាជអាជ្ញាជាតិ និងអន្តរជាតិ បានខ្វែងយោបល់គ្នាចំពោះការចេញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរក្នុងសំណុំរឿង ០០៤ នេះ ដោយសហព្រះរាជអាជ្ញាអន្តរជាតិស្នើសុំបញ្ជូនដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទី ៣។ រីឯសហព្រះរាជអាជ្ញាជាតិបានបដិសេធចោលនូវដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទី ៣ ផ្អែកលើមូលដ្ឋាន "ជនសង្ស័យទាំងនេះ មិនមែនជាមេដឹកនាំជាន់ខ្ពស់ និង/ឬ អ្នកទទួលខុសត្រូវខ្ពស់បំផុត"[19] ហើយចៅក្រមជាតិ និងអន្តរជាតិនៃអង្គបុរេជំនុំជម្រះ ក៏បានខ្វែងយោបល់គ្នាចំពោះបញ្ហានេះដែរ ដោយចៅក្រមជាតិនៃអង្គបុរេជំនុំជម្រះ គាំទ្រទឡ្ហីករណ៍របស់សហព្រះរាជអាជ្ញាជាតិ[20]។

19. ចៅក្រមជាតិនៃអង្គបុរេជំនុំជម្រះធ្លាប់សម្រេចម្តងរួចហើយថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនចាំបាច់ធ្វើកិច្ចស៊ើបសួរ ឬស៊ើបសួរបន្ថែមណាមួយ នៅក្នុងសំណុំរឿង ០០៤ ទៀតឡើយ។[21] ដូច្នេះមិនមានភាពចាំបាច់ណាមួយដែលតម្រូវឱ្យចៅក្រមជាតិធ្វើការពិចារណាទៅលើសំណើសុំ ឬពាក្យបណ្តឹងដែលមានកម្មវត្ថុដូចគ្នានេះទេ។

20. តាមការយល់ឃើញខាងលើនេះ ចៅក្រមជាតិនៃអង្គបុរេជំនុំជម្រះសម្រេចបដិសេធបណ្តឹងឧទ្ធរណ៍នេះ។

**ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃ០៣ ខែមេសា ឆ្នាំ២០១៧**

**ប្រធាន ប្រាក់ គឹមសាន** | **ចៅក្រម ន៉ី ថុល** | **ចៅក្រម ហួត វុទ្ធី**

---

[19] ចម្លើយតបរបស់សហព្រះរាជអាជ្ញាជាតិទៅនឹងសេចក្តីណែនាំឱ្យដាក់ឯកសារពិស្តារបន្ថែមរបស់អង្គបុរេជំនុំជម្រះ ចុះថ្ងៃទី ២៤ ខែមេសា ឆ្នាំ២០០៩ និងសេចក្តីសង្កេតរបស់សហព្រះរាជអាជ្ញាជាតិ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ២០០៩ កថាខណ្ឌទី ៨៦ (ក)។

[20] យោបល់របស់ចៅក្រម ប្រាក់ គឹមសាន, ចៅក្រម ន៉ី ថុល និងចៅក្រម ហួត វុទ្ធី ចុះថ្ងៃទី១៧ ខែ សីហា ឆ្នាំ២០០៩ "[redacted] មិនមែនជា មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម"។

[21] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងសេចក្តីសម្រេចលើសំណើលើកទីប្រាំរបស់ [redacted] ស្នើសុំបំពេញកិច្ចស៊ើបសួរ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៦ កថាខណ្ឌទី៣០ ឯកសារលេខD260/1/1/3។

01429659



21. សហមេធាវីផ្តល់ទឡ្ហីករណ៍តវ៉ាថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសនៅក្នុង៖ ការបកស្រាយមិនត្រឹមត្រូវលើលក្ខខណ្ឌស្តីពីភាពជាក់លាក់ និងខកខានមិនបានពិចារណាថា មេធាវីការពារក្តីមិនអាចធ្វើការស៊ើបអង្កេតដោយខ្លួនឯងបានយោងតាមក្រមខណ្ឌគតិយុត្តនៃ អ.វ.ត.ក (ខ) តម្រូវឱ្យមេធាវីការពារក្តីបង្ហាញលើសពីហេតុផល *បឋម*ថា កិច្ចស៊ើបសួរដែលបានស្នើសុំអាចផ្តល់ភ័ស្តុតាងដោះបន្ទុក និង (គ) បកស្រាយមិនត្រឹមត្រូវលើច្បាប់ អ.វ.ត.ក ហើយនឹងយកភាពឆាប់រហ័សមកដាក់ពីលើសិទ្ធិរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ក្នុងការត្រៀមរៀបចំការការពារក្តី[22]។

**ក. ការអនុវត្តលក្ខខណ្ឌស្តីពីភាពជាក់លាក់**

១. <u>ទឡ្ហីករណ៍</u>

22. សហមេធាវីអះអាងថា ទោះបីជាបានដកស្រង់យ៉ាងត្រឹមត្រូវអំពីបទដ្ឋានជាធរមានក៏ដោយ ក៏សហចៅក្រមស៊ើបអង្កេតអន្តរជាតិខកខានមិនបានវាយតម្លៃទៅតាមករណីនីមួយៗអំពីលក្ខខណ្ឌស្តីពីភាពជាក់លាក់ចំពោះសំណើតូចៗសុំស្តាប់ចម្លើយអតីតសមាជិកយោធាអំពីរចនាសម្ព័ន្ធបញ្ជា និងការមើលឃើញនូវភាពខុសគ្នារវាងឯកសណ្ឋាន និងសំលៀកបំពាក់[23]។ ចំណុចទីមួយ សហមេធាវីសន្និដ្ឋានថា ការទាមទារនូវព័ត៌មានលម្អិតបន្ថែមលើសពីប្រភេទសាក្សីដែលត្រូវស្តាប់ចម្លើយ ទីតាំងភូមិសាស្ត្ររបស់ពួកគេនៅអំឡុងពេលនៃហេតុការណ៍ពាក់ព័ន្ធ និងព័ត៌មានស្នើសុំពីពួកគេនឹងដាក់បន្ទុកឱ្យមេធាវីការពារក្តីស៊ើបអង្កេតដោយខ្លួនឯង រួមទាំង ការចុះពិនិត្យដល់ទីតាំង និងការស្តាប់ចម្លើយហួសពីដែនកំណត់នៃការសាកសួរបឋម ដែលត្រូវបានហាមឃាត់អនុលោមតាមក្របខណ្ឌគតិយុត្តនៃ អ.វ.ត.ក[24]។ ចំណុចទីពីរ ដោយបានសំអាងលើសេចក្តីសម្រេចមុនមួយលើសំណើសុំរបស់សហព្រះរាជអាជ្ញា សហមេធាវីអះអាងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានអនុវត្ត

[22] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ២។

[23] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៣១ ដល់ កថាខណ្ឌ ៣៣។

[24] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៣០ កថាខណ្ឌ ៣៤ ដល់ កថាខណ្ឌ ៣៧។

បទដ្ឋានចំពោះសំណើសុំរបស់មេធាវីការពារក្តីខ្ពស់ជាងបទដ្ឋានចំពោះសំណើសុំរបស់សហព្រះរាជអាជ្ញាអន្តរជាតិ[25]។

23. ជារួមមក សហព្រះរាជអាជ្ញាឆ្លើយតបថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានបកស្រាយ និងអនុវត្តច្បាប់ពាក់ព័ន្ធយ៉ាងត្រឹមត្រូវ[26]។

## ២. កិច្ចពិភាក្សា

24. ចៅក្រមកត់សម្គាល់ឃើញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានរកឃើញសំណើតូចសុំឱ្យកំណត់អត្តសញ្ញាណនិងស្តាប់ចម្លើយអតីតសមាជិកកងឈ្លបអំពីរចនាសម្ព័ន្ធបញ្ជាថាមាន "លក្ខណៈពុំជាក់លាក់" ដោយសារវា "វាតម្រូវឱ្យកិច្ចស៊ើបសួរនៅតាមទីតាំងភូមិសាស្ត្រទូលំទូលាយរួមទាំងទីតាំងដែលពុំជាប់ទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្មនានាដូចបានចោទប្រកាន់នៅក្នុង[ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបីផងដែរ]"[27]។ ស្រដៀងគ្នានេះដែរ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានពិចារណាឃើញថា សំណើតូចសុំឱ្យស្តាប់ចម្លើយសាក្សីអំពីភាពខុសគ្នារវាងឯកសណ្ឋាន និងសំលៀកបំពាក់ "មានលក្ខណៈទូលាយពេកមិនអាចបំពេញតាមលក្ខខណ្ឌស្តីពីភាពជាក់លាក់បាន"[28]។

25. ចៅក្រមសូមរំលឹកថា សាក្សីដែលបានស្នើសុំពុំចាំបាច់មានឈ្មោះជាក់លាក់នោះទេ[29]។ ដូច្នេះសំណើសុំដែលទំនងជាពង្រីកការស្តាប់ចម្លើយរហូតដល់បុគ្គលគ្មានឈ្មោះ និងពុំស្គាល់ទីកន្លែងអាចបំពេញលក្ខខណ្ឌស្តីពីភាពជាក់លាក់បានត្រឹមត្រូវ។ ចៅក្រមបានសង្កេតឃើញបន្ថែមទៀតថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិពុំទាមទារឱ្យមេធាវីការពារក្តីដាក់ឈ្មោះ ឬ កំណត់ទីតាំង

---

[25] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៣០ កថាខណ្ឌ ៣៨ ដល់ កថាខណ្ឌ ៤០ *ដែលយោងលើ* សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឱ្យបំពេញកិច្ចស៊ើបសួរទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្មនៃសំណុំរឿង ០០៤ និងការទទួលខុសត្រូវរបស់ [redacted] ចុះថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១៦ ឯកសារ D41/2 ("សេចក្តីសម្រេចលើសំណើសុំរបស់សហព្រះរាជអាជ្ញា")។

[26] ចម្លើយតប កថាខណ្ឌ ១។

[27] ដីកាសម្រេចដែលត្រូវបានជំទាស់ កថាខណ្ឌ ២៣។

[28] ដីកាសម្រេចដែលត្រូវបានជំទាស់ កថាខណ្ឌ ២៣។

[29] សំណុំរឿង ០០២ (អ.ប.ជ ៥០ & អ.ប.ជ ៥១) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី និងលោក នួន ជា ប្រឆាំងនឹងដីកាសម្រេចរបស់ ក.ស.ច.ស លើសំណើសុំឱ្យកោះហៅសាក្សី ចុះថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០១០ D314/1/8 ("សាលដីកាលើសំណើសុំកោះហៅសាក្សី") កថាខណ្ឌ៤៩។

សាក្សីនោះទេ[30] ហើយសហមេធាវីពុំចង្អុលបញ្ជាក់លើសំអាងហេតុដែលត្រូវបានជំទាស់ជាក់លាក់ ដើម្បីគាំទ្រការអះអាងបែបនេះឡើយ។ ផ្ទុយទៅវិញ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានរកឃើញយ៉ាងត្រឹមត្រូវថា សំណើទូលាយសុំកំណត់អត្តសញ្ញាណ "កងទ័ពបដិវត្តន៍កម្ពុជាទាំងអស់ និងកងសន្តិសុខផ្សេងទៀត"[31] ដែលធ្វើប្រតិបត្តិការនៅភូមិភាគកណ្តាលនៅក្នុងអំឡុងពេលបោសសម្អាតដូចបានចោទប្រកាន់ និង "សាក្សី"[32]ដែលអាចផ្តល់ភស្តុតាងអំពីឯកសណ្ឋាន និងសំដីសំដៅ ទោះបីជាផ្តល់ការចង្អុលបញ្ជាក់ទូទៅអំពីលក្ខណៈនៃការស៊ើបអង្កេតដែលបានស្នើសុំក៏ដោយ ប្រាកដណាស់ថាពុំបានបំពេញលក្ខខណ្ឌស្តីពីភាពជាក់លាក់នោះឡើយ។

26. ចៅក្រមក៏បានច្រានចោលទឡ្ហីករណ៍អំពីការរំលោភសមភាពរវាងគូភាគីក្តីដូចបានចោទប្រកាន់ និងបទដ្ឋានផ្សេងគ្នាដែលត្រូវបានអនុវត្តលើសហព្រះរាជអាជ្ញាអន្តរជាតិដោយសារចៅក្រមបានសន្និដ្ឋាន រួចហើយថា មេធាវីការពារក្តីពុំដែលត្រូវបានទាមទារឱ្យបង្ហាញឈ្មោះសាក្សីនោះទេ។ លើសពីនេះ ចៅក្រមសង្កេតឃើញថា សេចក្តីសម្រេចដែលសហមេធាវីសំអាងក្នុងការបង្ហាញបទដ្ឋានខុសគ្នាដូចបានត្រូវអនុវត្តពុំបានអនុញ្ញាតតាមសំណើសុំរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ហើយក៏បានវាយតម្លៃភាពពុំជាក់លាក់ដូចបានចោទប្រកាន់ ហើយសេចក្តីសម្រេចនេះគ្រាន់តែបានលើកឡើងថាកិច្ចស៊ើបសួរត្រូវបានបំពេញរួចហើយ[33]។ ហេតុដូច្នេះ ម្ចាស់បណ្តឹងឧទ្ធរណ៍ពុំបានបង្ហាញអំពីការរំលោភសមភាពរវាងគូភាគីក្តីដែលនឹងនាំឱ្យអង្គបុរេជំនុំជម្រះចូលអន្តរាគមន៍។

27. អាស្រ័យហេតុនេះ ចៅក្រមសន្និដ្ឋានថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានអនុវត្តលក្ខខណ្ឌតេស្តសមស្របចំពោះបទដ្ឋានសមស្របនៅពេលវាយតម្លៃភាពជាក់លាក់នៃសំណើតូចៗចំនួនពីរ ហើយច្រានចោលមូលដ្ឋានទីមួយនៃបណ្តឹងឧទ្ធរណ៍។

## ខ. ការអនុវត្តលក្ខខណ្ឌបច្ចុប្បន្នស្តីពីភាពជោះបន្ទុក

### ១. ទឡ្ហីករណ៍

[30] ដីកាសម្រេចដែលត្រូវបានជំទាស់ កថាខណ្ឌ ១៨ កថាខណ្ឌ ២៣។

[31] សំណើសុំលើកទីប្រាំពីរ កថាខណ្ឌ ២៤។

[32] សំណើសុំលើកទីប្រាំពីរ កថាខណ្ឌ ២៥។

[33] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៣៩ *ដែលយោងលើ* សេចក្តីសម្រេចលើសំណើសុំរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១៩ កថាខណ្ឌ ៣១ កថាខណ្ឌ ៤៨ និងទំព័រ ១១។

28. ដោយនឹកឃើញនូវយុត្តិសាស្ត្ររបស់អង្គបុរេជំនុំជម្រះ និងអន្តរជាតិ[34] ម្ចាស់បណ្តឹងឧទ្ធរណ៍អះអាងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសនៅក្នុងការអនុវត្តបទដ្ឋានខ្ពស់ជាងមុន និងពុំត្រឹមត្រូវ ហើយតម្រូវឱ្យសហចៅក្រមស៊ើបអង្កេតអន្តរជាតិបង្ហាញតម្លៃភស្តុតាងដោះបន្ទុកលើសពីកម្រិតបឋមដែលត្រូវបានស្នើសុំនៅក្នុងសំណើសុំតូចៗរបស់គាត់ចំនួនបី[35]។ សហមេធាវីលើកឡើងថា សហមេធាវីបានបង្ហាញរឿងក្តីមួយគួរឱ្យជឿជាក់ក្រោមបទដ្ឋានត្រឹមត្រូវក្នុងកម្រិតទាប កិច្ចដែលបានស្នើសុំនឹងរកឃើញនូវភស្តុតាងដោះបន្ទុក ហើយនឹងបង្ហាញភស្តុតាង *បឋម*ថាកម្លាំងផ្សេងទៀតអាចជាអ្នកទទួលខុសត្រូវលើការបោសសម្អាតដែលត្រូវបានចោទប្រកាន់នៅក្នុងភូមិភាគកណ្តាល[36]។ ជាពិសេស សហមេធាវីសន្និដ្ឋានថា ខុសពីសំអាងហេតុនៅក្នុងដីកាសម្រេចដែលត្រូវបានជំទាស់ មេធាវីការពារក្តីចង្អុលលើសពីកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី [redacted] ជាភស្តុតាង *បឋម* ដែលគាំទ្រសំណើសុំរបស់ពួកគេ រួមទាំង ភស្តុតាងពី [redacted] និង [redacted] ផងដែរ[37]។

29. សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា សហមេធាវីខកខានមិនបានបង្ហាញថាតើរចនាសម្ព័ន្ធបញ្ជានៃយោធា និងកងកម្លាំងសន្តិសុខ ដែលគ្មានហេតុផលគួរឱ្យជឿជាក់ថា ពួកគេពាក់ព័ន្ធនឹងការបោសសម្អាតនៅតំបន់ ៤១ ហើយសំដីសំដៅរបស់បុគ្គលដែលចូលរួមនៅក្នុងការបោះសម្អាតផងនោះ អាចនឹងពាក់ព័ន្ធនឹងសំណុំរឿង ០០៤/០២ ឬ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍[38]។

## ២. <u>កិច្ចពិភាក្សា</u>

[34] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៤៤ ដល់ កថាខណ្ឌ ៤៧។

[35] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៤៣ កថាខណ្ឌ ៤៨។

[36] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៤៨ ដល់ កថាខណ្ឌ ៤៩។

[37] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៤៨ *ដែលយោងលើ* ដីកាសម្រេចដែលត្រូវបានជំទាស់ កថាខណ្ឌ ១៨ កថាខណ្ឌ ២៤ កថាខណ្ឌ ២៥ និងកថាខណ្ឌ ២៧ និងសំណើសុំលើកទីប្រាំពីរ កថាខណ្ឌ ១៥ ដល់ កថាខណ្ឌ ១៦ កថាខណ្ឌ ១៨ ដល់ កថាខណ្ឌ ២៤ កថាខណ្ឌ ២៧ ដល់ កថាខណ្ឌ ៣០។

[38] ចម្លើយតប កថាខណ្ឌ ២ ដល់ កថាខណ្ឌ ៣។

30. ចៅក្រមនឹកឃើញថា សហចៅក្រមស៊ើបអង្កេត "[ខ្លួន]ត្រូវពិនិត្យបានពិនិត្យមើលសម្ភារៈផ្សេងៗទៀតនៅពេលមានមូលហេតុ*បឋម*នាំឱ្យជឿជាក់ថា ឯកសារទាំងនោះអាចជាភស្តុតាងដោះបន្ទុក"[39]។ ហេតុដូច្នេះ កត្តាកំណត់នោះគឺត្រង់ថាតើសហចៅក្រមស៊ើបអង្កេតជឿជាក់ថា ភាគីស្នើសុំបានបង្ហាញហេតុផល*បឋម*គួរឱ្យជឿជាក់ថា កិច្ចដែលបានស្នើសុំអាចបង្ហាញភស្តុតាងដោះបន្ទុកដែរឬទេ[40]។ វាពុំគ្រប់គ្រាន់ក្នុងការសំដៅលើឯកសារថា "ពាក់ព័ន្ធ" និង "ចាំបាច់ចំពោះការការពារក្តី" ហើយនឹងគ្រាន់តែអះអាងថា ឯកសារទាំងនេះមានភស្តុតាងដោះបន្ទុកដោយពុំបានធ្វើការពន្យល់បន្ថែមអំពីករណីថាតើឯកសារទាំងនេះអាចបង្ហាញភាពគ្មានទោស ឬ សម្រាលការទទួលខុសត្រូវបុគ្គលដែរឬយ៉ាងណា[41]។

31. នៅក្នុងដីកាសម្រេចដែលត្រូវបានជំទាស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានកត់សម្គាល់ឃើញ "នត្ថិភាពនៃការចង្អុលបញ្ជាក់*បឋម*ថា កងកម្លាំងពីក្រៅតំបន់ ៤១ បានចូលរួមពាក់ព័ន្ធនៅក្នុងឧក្រិដ្ឋកម្មដូចបានចោទប្រកាន់នៅក្នុង[ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបី]"[42]ហើយបាន រកឃើញបន្ថែមទៀតថាមានភស្តុតាង "តិចតួច"[43] ស្តីពីការចូលរួមពាក់ព័ន្ធរបស់យោធាតំបន់ ១០៦។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិក៏ពិចារណាលើអានុភាពនៃភស្តុតាងដោះបន្ទុកថាជាការទាយស្មាន

---

[39] សាលដីកាលើឃ្លាំងផ្ទុកឯកសាររួម កថាខណ្ឌ ៣៥។

[40] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ កថាខណ្ឌ ៤៧។

[41] សំណុំរឿង ០០២ (អ.ប.ជ ៤៩) សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់ ក.ស.ច.ស ចំពោះសំណើរបស់លោក នួន ជា សុំឱ្យមានកិច្ចស៊ើបសួរទាក់ទងនឹងរដ្ឋបរទេស និងសាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចទាក់ទងនឹងសំណើសុំបើកកិច្ចស៊ើបសួរពាក់ព័ន្ធរដ្ឋបរទេសចំពោះការទាត់ចោលសំណើសុំស្តាប់ចម្លើយសាក្សីដែលធ្វើឡើងដោយលោក ខៀវ សំផន ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១០ ឯកសារ D315/1/5 កថាខណ្ឌ ២១។ សំណុំរឿង ០០២ (អ.ប.ជ ៥៤) សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់ ក.ស.ច.ស ចំពោះសំណើសុំរបស់លោក នួន ជា សុំឱ្យមានកិច្ចស៊ើបសួរទាក់ទងនឹងរដ្ឋបរទេស និងសាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចទាក់ទងនឹងសំណើសុំបើកកិច្ចស៊ើបសួរពាក់ព័ន្ធរដ្ឋបរទេសចំពោះការទាត់ចោលសំណើសុំស្តាប់ចម្លើយសាក្សីដែលធ្វើឡើងដោយលោក ខៀវ សំផន ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១០ ឯកសារ D315/2/2 កថាខណ្ឌ ២១។

[42] ដីកាសម្រេចដែលត្រូវបានជំទាស់ កថាខណ្ឌ ១៨។

[43] ដីកាសម្រេចដែលត្រូវបានជំទាស់ កថាខណ្ឌ ២៧។

និងពុំជាក់លាក់ដែលបង្ហាញថា កងកម្លាំងខ្លះដែលធ្វើប្រតិបត្តិការនៅភូមិភាគកណ្តាលមានសំដីសំដៅ ឬ ឯកសារដោយឡែក[44]។

32. តាមពិតទៅ ចៅក្រមសង្កេតឃើញថា ក្រៅពីការត្រឹមតែលើកឡើងថា កិច្ចស៊ើបសួរដែលបានស្នើសុំ "ចាំបាច់ត្រូវធ្វើឡើង និងពាក់ព័ន្ធនឹងការបញ្ជាក់ការពិតអំពីអត្តសញ្ញាណនៃអ្នកទាំងឡាយដែលទទួលខុសត្រូវខ្ពស់"[45] ហើយចង្អុលបង្ហាញភស្តុតាងនៅក្នុងសំណុំរឿងដែលបញ្ជាក់ថា កងកម្លាំងផ្សេងទៀតអាចជាអ្នកទទួលខុសត្រូវលើការបោសសម្អាត[46] សហមេធាវីពុំបានពន្យល់នៅក្នុងសំណើសុំលើកទីប្រាំពីរថាតើភស្តុតាងដែលបានស្នើសុំនោះអាចបង្ហាញភាពគ្មានទោសរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ ឬ សម្រាលការទទួលខុសត្រូវរបស់គាត់ដោយរបៀបណា។ នៅក្នុងសំណុំរឿងអត្ថិភាពនៃរឿងរ៉ាវរបស់សាក្សីជាច្រើនជាការលើកឡើងនៅក្នុងដីកាសម្រេចដែលត្រូវបានជំទាស់[47]ពុំច្រានចោលភាពចាំបាច់សម្រាប់មេធាវីការពារក្តីពន្យល់ឱ្យបានច្បាស់លាស់ថាតើ ចម្លើយ បែបនេះនៅពេលបញ្ចូលគ្នាអាចបង្ហាញភាពគ្មានទោសរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ ឬ សម្រាលការទទួលខុសត្រូវរបស់គាត់ដោយរបៀបណា[48]។ ស្រដៀងគ្នានេះដែរ ការលើកឡើងថា "ការស៊ើបសួរបន្ថែមលើ [សំឡេងនិយាយ និងឯកសណ្ឋាន] អាចជួយឱ្យសហចៅក្រមស៊ើបអង្កេតកំណត់អត្តសញ្ញាណកងកម្លាំងទាំងឡាយដែលប្រតិបត្តិការនៅលើទឹកដីនៃភូមិភាគកណ្តាល(ឧត្តរចាស់) នៅក្នុងអំឡុងពេលនៃការបោសសម្អាតដែលត្រូវបានចោទប្រកាន់"[49] គឺពុំគ្រប់គ្រាន់អាចឱ្យសហចៅក្រមស៊ើបអង្កេតជឿជាក់ និងយកតាមតម្រុយទាំងនេះឡើយ។ ជាពិសេស សហមេធាវីពុំបានបង្ហាញថាតើហេតុផលគួរឱ្យជឿជាក់ថា ការចូលរួមរបស់កងយោធាផ្សេងទៀតនៅក្នុងភូមិភាគនោះអាចមានឥទ្ធិពលលើការវាយតម្លៃលើការទទួលខុសត្រូវរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ដោយរបៀបណាជាពិសេសក្រោយពីពិនិត្យភស្តុតាងដែលបានប្រមូលរួចអស់ហើយអំពីសិទ្ធិអំណាចដែលម្ចាស់បណ្តឹងឧទ្ធរណ៍មានលើតាមទីតាំងឧក្រិដ្ឋកម្មក្រោមការស៊ើបអង្កេត រួមទាំង តាមរយៈការចេញ ឬ ការ

[44] ដីកាសម្រេចដែលត្រូវបានជំទាស់ កថាខណ្ឌ ២៤។

[45] សំណើសុំលើកទីប្រាំពីរ កថាខណ្ឌ ២៦ និង កថាខណ្ឌ ៣៤។

[46] សំណើសុំលើកទីប្រាំពីរ កថាខណ្ឌ ១៨ ដល់ កថាខណ្ឌ ២៤ កថាខណ្ឌ ២៧ ដល់ កថាខណ្ឌ ៣០។ *សូមមើលផងដែរ* សំណើសុំលើកទីប្រាំពីរ លេខយោងជើងទំព័រ ៤៩ និង ៥២ *ដែលយោងលើ* ចម្លើយរបស់ [redacted] និង [redacted]

[47] *សូមមើល* បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៤៨។

[48] *សូមមើលផងដែរ* សំណើសុំលើកទីប្រាំពីរ កថាខណ្ឌ ១៥ ដល់ កថាខណ្ឌ ១៦។

[49] សំណើសុំលើកទីប្រាំពីរ កថាខណ្ឌ ២៥។



PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C. C.E.T.C.

បញ្ជូនបញ្ញាបន្ត[50]។ សរុបមកវិញ សហចៅក្រមស៊ើបអង្កេតបានសំអាងត្រឹមត្រូវលើកាលៈទេសៈនៃអង្គហេតុនៅក្នុងរឿងក្តី ដូចបានបង្ហាញតាមរយៈភស្តុតាងដែលមាននៅក្នុងសំណុំរឿងស្រាប់រួចហើយដើម្បីសន្និដ្ឋានថាមេធាវីការពារក្តីពុំបានបញ្ជាក់បំភ្លឺអានុភាពដោះបន្ទុកនៃភស្តុតាងត្រឹមកម្រិតមួយដែលថា សំណើសុំនេះអាចបំពេញលក្ខខណ្ឌ *បឋម*ស្តីពីភស្តុតាងដោះបន្ទុក។

33. ហេតុដូច្នេះ ដោយកត់សម្គាល់ឃើញថា ចៅក្រមបានសម្រេចរួចហើយថា លក្ខខណ្ឌត្រួតស្តីពីភាពជាក់លាក់ពុំបានបំពេញទាក់ទងនឹងសំណើសុំតូចៗចំនួនពីរ[51] ហេតុដូច្នេះ ចៅក្រមពុំរកឃើញកំហុសនៅក្នុងការអនុវត្តរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិលើលក្ខខណ្ឌ *បឋម*ស្តីពីភស្តុតាងដោះបន្ទុក។ ដូច្នេះ មូលដ្ឋានទីពីរនៃបណ្តឹងឧទ្ធរណ៍ត្រូវបានច្រានចោល។

## គ. តើ ស.ច.ស.អ បានជាក់ភាពឆាប់រហ័សនៅក្នុងការបិទកិច្ចស៊ើបសួរ លើសិទ្ធិរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ដែរឬទេ

### ១. ទឡ្ហីករណ៍

34. សហមេធាវីតវ៉ាថា នៅក្នុងការសម្រេចថា សំណើសុំតូចៗចំនួនពីរសុំដាក់ក្នុងសំណុំរឿងនូវកំណត់ត្រា និងខ្សែអាត់ពី Alexander Hinton និង Steven Heder អាចនឹងចំណាយពេលយូរ ឬ ពិបាក សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានដាក់ភាពឆាប់រហ័សនៅក្នុងការបិទកិច្ចស៊ើបសួរលើសិទ្ធិរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍នៅក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌[52]។ សហមេធាវីសន្និដ្ឋានថា បទដ្ឋានស្តីពីការយល់ព្រមតាមសំណើសុំបំពេញកិច្ចស៊ើបសួរគឺថាតើលក្ខខណ្ឌស្តីពីភាពជាក់លាក់ និងលក្ខខណ្ឌ *បឋម*ស្តីពីភាពពាក់ព័ន្ធ និងភស្តុតាងដោះបន្ទុកបានបំពេញដែរឬទេ[53]។

35. ជាពិសេស សហមេធាវីអះអាងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសនៅក្នុងការបដិសេធការប្រើប្រាស់អំណាចរបស់ខ្លួនក្នុងការសុំកំណត់ត្រា និងសម្ភារៈស្រាវជ្រាវរបស់ Hinton ពីព្រោះវិធានការចាប់បង្ខំ "អាចនៅទីបំផុតត្រូវការពេលវេលាច្រើនលើសលប់" ទោះបីជាគាត់បាន

---

[50] ដីកាសម្រេចដែលត្រូវបានជំទាស់ កថាខណ្ឌ ២៥។

[51] *សូមមើលដូចខាងលើ* កថាខណ្ឌ ២៧។

[52] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៥១ កថាខណ្ឌ ៥៥។

[53] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៥១។



PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C. C.E.T.C

ទទួលស្គាល់ថាភស្តុតាងដែលបានស្នើសុំអាចគាំទ្ររឿងក្តីរបស់មេធាវីការពារក្តីក៏ដោយ[54]។ ស្រដៀងគ្នានេះដែរសហមេធាវីតវ៉ាលើការខកខានរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិក្នុងការប្រើប្រាស់ឱ្យ អស់នូវមធ្យោបាយដែលមានដើម្បីទទួលបានកំណត់ត្រា និងខ្សែអាត់របស់ Heder ដោយសារគាត់បានប្រកាសថា សំណើសុំនោះ “ពុំទទួលបានផ្លែផ្កា និងលុបចោល” ដោយពុំបានប្រឹងប្រែងទាក់ទង Heder ក្រៅពីការព្យាយាមតែមួយលើកគត់ ឬ ពុំបានប្រឹងប្រែងបង្ហាប់វិធានការចាប់បង្ខំ[55]។

36. សហព្រះរាជអាជ្ញាឆ្លើយតបជារួមថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានបកស្រាយ និងអនុវត្តត្រឹមត្រូវនូវច្បាប់ពាក់ព័ន្ធ ហើយបានសម្រេចទៅក្នុងដែនឆន្ទានុសិទ្ធិរបស់ខ្លួននៅក្នុងការច្រានចោលសំណើសុំបំពេញកិច្ចស៊ើបសួរនេះ[56]។

## ២. កិច្ចពិភាក្សា

37. ចៅក្រមទទួលស្គាល់ថា បទដ្ឋានក្នុងការយល់ព្រមតាមសំណើសុំបំពេញកិច្ចស៊ើបសួរគឺពុំមែនថាតើសំណើសុំទាំងនោះចំណាយពេលច្រើន ឬ ពិបាកនោះទេ ប៉ុន្តែ ដូចបានលើកឡើងខាងលើ គឺថាតើសំណើសុំទាំងនោះបានបំពេញលក្ខខណ្ឌស្តីពីភាពជាក់លាក់ និងលក្ខខណ្ឌ*បឋម*ស្តីពីភាពពាក់ព័ន្ធដែរឬទេ។ ទោះបីជាយ៉ាងនេះក្តី ចៅក្រមក៏សូមរំលឹកផងដែរថា សហចៅក្រមស៊ើបអង្កេតមានឆន្ទានុសិទ្ធធំធេងនៅក្នុងការវាយតម្លៃលើសំណើសុំបំពេញកិច្ចស៊ើបសួរ[57] ហើយសហចៅក្រមស៊ើបអង្កេតនៅតែមានឆន្ទានុសិទ្ធិនេះក្នុងការសម្រេចលើភាពចាំបាច់ ឬ ឱកាសក្នុងការបំពេញកិច្ចស៊ើបសួរ ហើយករណីនេះកើតឡើងនៅពេលលក្ខខណ្ឌអប្បបរមាត្រូវបានបំពេញ[58]។ ដូច្នេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិពុំមានភារកិច្ចប្រើប្រាស់មធ្យោបាយឱ្យអស់ដែលខ្លួនមានដើម្បីប្រមូលឯកសារពាក់ព័ន្ធ ប៉ុន្តែ នៅក្នុងការបំពេញភារកិច្ចរបស់ខ្លួនក្នុងការបញ្ជាក់ការពិត សហ

[54] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៥៥។

[55] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៥៦។

[56] ចម្លើយតប កថាខណ្ឌ ១។

[57] *សូមមើល ឧ.* សាលដីកាលើសំណើសុំកោះហៅសាក្សី កថាខណ្ឌ ២៨។ សេចក្តីសម្រេចលើឃ្លាំងផ្ទុកឯកសាររួម កថាខណ្ឌ ២២។

[58] សាលដីកាស្តីពីការពិចារណាឡើងវិញលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៥៧។

ចៅក្រមស៊ើបអង្កេតអន្តរជាតិមានភារកិច្ចសម្រេចថាតើសម្ភារៈដែលបានស្នើសុំមានសារប្រយោជន៍ក្នុងការបំពេញកិច្ចស៊ើបសួរដែរឬទេ។

*ក) កំណត់ត្រាស្រាវជ្រាវរបស់ Hinton*

38. ចៅក្រមពិចារណាឃើញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានទទួលស្គាល់ដោយប្រយោលអំពីភាពពាក់ព័ន្ធ នឹងភាពជាក់លាក់នៃសំណើសុំដោយបានព្យាយាមប្រមូលកំណត់ត្រា និងសម្ភារៈស្រាវជ្រាវរបស់ Hinton ដែលនៅទីបំផុតបដិសេធពុំទាក់ទងពួកគេដោយសារលក្ខខណ្ឌនៃការការពារបុគ្គលរបស់សាកលវិទ្យាល័យនៃសហរដ្ឋអាមេរិក[59]។ ដូច្នេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិពុំបានច្រានចោលសំណើសុំតូចនោះទេពីព្រោះលក្ខខណ្ឌអប្បបរមាពុំបានបំពេញ ឬដោយសារបញ្ហាចោទថា ភស្តុតាងបែបនេះអាចត្រូវបានប្រមូលត្រឹមត្រូវរួចអស់ហើយ។ ផ្ទុយមកវិញ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានប្រើប្រាស់អំណាចឆន្ទានុសិទ្ធិដ៏ទូលំទូលាយរបស់ខ្លួនដើម្បីថ្លឹងថ្លែងការវាយតម្លៃរបស់គាត់លើសារប្រយោជន៍នៃកំណត់ត្រា និងសម្ភារៈស្រាវជ្រាវរបស់ Hinton និងការលំបាកពាក់ព័ន្ធនឹងការអនុវត្តវិធានការចាប់បង្ខំនៅមុនពេលសន្និដ្ឋានថាសហចៅក្រមស៊ើបអង្កេតអន្តរជាតិពុំយល់ឃើញថា "សមស្រប" នៅក្នុងការប្រើប្រាស់វិធានការបែបនេះ "នៅក្នុងកាលៈទេសៈទាំងនេះឡើយ"[60]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានផ្តល់សារសំខាន់ខ្លាំងលើករណីដែលថាកំណត់សម្គាល់ដែលបានស្នើសុំ "ត្រឹមតែបំពេញបន្ថែមលើសៀវភៅរបស់ Alexander Hinton" ដែលមាននៅក្នុងសំណុំរឿងរួចហើយ ហើយមកទល់ពេលនេះ ពុំមានហេតុផលត្រូវសង្ស័យលើភាពអាចទុកចិត្តបាននៃការស្រាវជ្រាវនេះឡើយ[61]។

39. ជាការពិតណាស់ ចៅក្រមជឿជាក់ថា សៀវភៅរបស់ Hinton ដែលមេធាវីការពារក្តីបានយកមកជាសំអាងសម្រាប់សំណើសុំ[62] មាននៅក្នុងសំណុំរឿងរួចហើយ ហើយវាគ្មានហេតុផលត្រូវសង្ស័យលើភាពអាចទុកចិត្តបាននៃស្នាដៃនិពន្ធមួយនេះ ហេតុដូច្នេះ យើងពុំចាំបាច់ត្រូវផ្ទៀងផ្ទាត់ជាមួយនឹងសម្ភារៈផ្សេងទៀតដែលអ្នកនិពន្ធមាននោះទេ។ ចៅក្រមកត់សម្គាល់បន្ថែមទៀតប្រតិចារឹក នៃ

---

59 ដីកាសម្រេចដែលត្រូវបានជំទាស់ កថាខណ្ឌ ៣០។

60 ដីកាសម្រេចដែលត្រូវបានជំទាស់ កថាខណ្ឌ ៣១។

61 ដីកាសម្រេចដែលត្រូវបានជំទាស់ កថាខណ្ឌ ៣១។

62 សំណើសុំលើកទីប្រាំពីរ កថាខណ្ឌ ១៨ និងលេខយោងជើងទំព័រ ៣៣។

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. * C.E.T.C.

សក្ខីកម្មរបស់ Hinton នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងក្នុងខែមីនា ឆ្នាំ២០១៦ដែលមាននៅក្នុងសំណុំរឿងរួចហើយ[63]។ ចៅក្រមក៏សង្កេតឃើញថា Hinton បានបញ្ជាក់ច្បាស់ថា ប្រភពចំបងរបស់គាត់រួមមានអ្នកសិក្សាស្រាវជ្រាវ David Chandler និង Ben Kiernan[64] ដែលស្នាដៃនិពន្ធរបស់ពួកគេក៏មាននៅក្នុងសំណុំរឿងរួចហើយដូចគ្នា[65] ហើយស្នាដៃសៀវភៅរបស់ Hinton បានផ្សាយចេញនៅក្នុងឆ្នាំ២០០៤ ដោយគ្មានការស្រាវជ្រាវបន្ថែមក្រោយពេលគាត់បាន ប្រមូលប្រភពរបស់គាត់នៅចន្លោះឆ្នាំ១៩៩៤ និងឆ្នាំ១៩៩៥[66]។

40. យោងតាមកាលៈទេសៈទាំងនេះ ចៅក្រមពុំជឿជាក់ថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានដាក់ភាពឆាប់រហ័សនៅក្នុងការបិទកិច្ចស៊ើបសួរលើសិទ្ធិរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌នោះទេ។ ផ្ទុយមកវិញ ចៅក្រមយល់ឃើញថា នៅពេលព្យាយាមប្រមូលភស្តុតាង ប៉ុន្តែពុំអាចទៅរួចនោះ ហើយនៅពេលពិចារណាថា កំណត់ត្រាស្រាវជ្រាវគ្រាន់តែគាំទ្រសៀវភៅរបស់ Hinton សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានបំពេញភារកិច្ចត្រឹមត្រូវក្នុងការបញ្ជាក់ការពិតអនុលោមតាមវិធាន ៥៥(៥) នៃវិធានផ្ទៃក្នុង និងមាត្រា ១២៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

*ខ) កំណត់ត្រា និងខ្សែអាត់កិច្ចសម្ភាសន៍របស់ Heder*

41. ស្រដៀងគ្នាដែរ ចៅក្រមពិចារណាថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិពុំមានកាតព្វកិច្ចប្រើប្រាស់លទ្ធភាពដែលមានទាំងអស់ឱ្យអស់ដើម្បីទទួលបានកំណត់ត្រា និងខ្សែអាត់របស់ Heder បើទោះជាលក្ខខណ្ឌអប្បបរមាត្រូវបានបំពេញរួចហើយនោះទេ។ ដូចបាននឹងឃើញពីករណីមុន

---

[63] ឯកសារ D219/792.1.6 ឯកសារ D219/792.1.7 ឯកសារ D219/792.1.8 និងឯកសារ D219/792.1.9។

[64] ឯកសារ D219/792.1.6 ទំព័រ ១៧ (ERB 01217257)។

[65] *សូមមើល* ក្នុងនោះ ឯកសារ D1.3.17.5 ឯកសារ D6.1.937 ឯកសារ D6.1.1104 (Kiernan) ឯកសារ D6.1.83 ឯកសារ D6.1.84 ឯកសារ D6.1.596 (Chandler)។

[66] ឯកសារ D219/792.1.6 ទំព័រ ៦ (ERN 01217246)។

សហចៅក្រមស៊ើបអង្កេតពុំមានកាតព្វកិច្ចគោរពតាមសំណើសុំនោះទេនៅពេលដែលសហចៅក្រមស៊ើបអង្កេតជឿជាក់ថា សំណើសុំនោះពុំជួយដល់ការបញ្ជាក់ការពិត[67]។

42. ជាពិសេស ចៅក្រមសង្កេតឃើញថា ភស្តុតាងដែលបានស្នើសុំពី Heder បានដាក់បញ្ចូលនៅក្នុងសំណើសុំស៊ើបអង្កេតលើតួនាទីរបស់ [redacted] និងការចូលរួមនៅក្នុងការបោសសម្អាតភូមិភាគកណ្តាលរួចហើយ[68] ដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានកត់សម្គាល់ឃើញថា ភស្តុតាងជាច្រើនមាននៅក្នុងសំណុំរឿងរួចហើយ[69]។ លើសពីនេះ ក្រោយពីមានសំណើសុំលើកទីប្រាំពីររួចហើយ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានបំពេញកិច្ចស៊ើបសួរពាក់ព័ន្ធនឹងតួនាទីរបស់ [redacted] និងដាក់បញ្ចូលនៅក្នុងសំណុំរឿងនូវឯកសារពាក់ព័ន្ធពីក្នុងសំណុំរឿងផ្សេងទៀតព្រមទាំងសៀវភៅចំណងជើងថា *ប្រល័យពូជសាសន៍នៅក្នុងប្រទេសកម្ពុជា៖ ឯកសារពីការជំនុំជម្រះ ប៉ុល ពត និង អៀង សារី*[70]។ ដោយប្រឈមនឹងនត្ថិភាពនៃការឆ្លើយតបពី Heder សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានសម្រេចដាក់បញ្ចូលនៅក្នុងសំណុំរឿងនូវរបាយការណ៍វិភាគមួយផងដែរដែលមានចំណងជើងថា *ការវាយតម្លៃឡើងវិញលើតួនាទីរបស់មេដឹកនាំជាន់ខ្ពស់ និងកម្មាភិបាលមូលដ្ឋាននៅក្នុងឧក្រិដ្ឋកម្មនៃរបបកម្ពុជាប្រជាធិបតេយ្យ៖សិទ្ធិអំណាចកម្ពុជានៅក្នុងទស្សនទានប្រៀបធៀប*[71]។

43. ដោយយល់ឃើញនូវអំណាចឆន្ទានុសិទ្ធិដ៏ទូលាយរបស់សហចៅក្រមស៊ើបអង្កេតក្នុងការវាយតម្លៃលើសំណើសុំបំពេញកិច្ចស៊ើបសួរដោយសារសហចៅក្រមស៊ើបអង្កេតយល់ដឹងសំណុំរឿង[72] ចៅក្រមយល់ឃើញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានបំពេញកិច្ចត្រឹមត្រូវនៅក្នុងដែនអំណាចឆន្ទានុសិទ្ធិរបស់ខ្លួនហើយគោលបំណងរួមក្នុងការស៊ើបអង្កេតលើតួនាទីរបស់ [redacted] នៅភូមិភាគកណ្តាលក្នុងការបញ្ជាក់ការពិតដូចបានលើកឡើងនៅក្នុងសំណើសុំលើកទីប្រាំពីរបានសម្រេចរួចហើយ។

---

[67] សំណុំរឿង ០០២ (អ.ប.ជ ៤០) សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតទៅលើសំណើលើកទីពីររបស់ នួន ជា សុំបំពេញកិច្ចស៊ើបសួរ ចុះថ្ងៃទី៥ ខែឧសភា ឆ្នាំ២០១០ ឯកសារ D100/9/2 កថាខណ្ឌ ២៣។

[68] សំណើសុំលើកទីប្រាំពីរ ទំព័រ ១១។

[69] ដីកាសម្រេចដែលត្រូវបានជំទាស់ កថាខណ្ឌ ៤១ កថាខណ្ឌ ៤៣។

[70] ដីកាសម្រេចដែលត្រូវបានជំទាស់ កថាខណ្ឌ ៤៣ កថាខណ្ឌ ៤៧។

[71] ដីកាសម្រេចដែលត្រូវបានជំទាស់ កថាខណ្ឌ ៤៨ ដល់ កថាខណ្ឌ ៤៩។

[72] សេចក្តីពិចារណាលើសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរលើកទីប្រាំ កថាខណ្ឌ ១៦។

44. អាស្រ័យហេតុនេះ ចៅក្រមប្រានចោលបណ្តឹងឧទ្ធរណ៍នេះទាំងស្រុង។

**ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃ០៣ ខែមេសា ឆ្នាំ២០១៧**

**ចៅក្រម** Olivier BEAUVALLET

**ចៅក្រម** Kang Jin BAIK

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C